I. ទីស្តីការគណៈរដ្ឋមន្ត្រី

អនុក្រឹត្យ

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៩៩៤

អនុក្រឹត្យលេខ ២០ អនក្រ ស្តីពី

ការបង្កើតអង្គភាពបង្ការ និងពន្លត់អគ្គិភ័យ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកតាមស្មារតីប្រជុំគណៈរដ្ឋមន្ត្រីពេញអង្គ នាថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៤

សម្រេច

មាត្រា ១ៈ បង្កើតអង្គភាពបង្ការ និង ពន្លត់អគ្គិភ័យមួយ ស្ថិតក្រោមការគ្រប់គ្រង របស់រាជធានីភ្នំពេញ និង ខេត្ត- ក្រុង

មាត្រា ២ : អង្គភាពបង្ការ និង ពន្លត់អគ្គិភ័យ មានតួនាទី និង ភារកិច្ចដូចតទៅ ÷

- បង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដោយអគ្គិភ័យ ដើម្បីការពារអាយុជីវិត ទ្រព្យសម្បត្តិជាតិ និងទ្រព្យសម្បត្តិរបស់ប្រជារាស្ត្រ ។
- រៀបចំបទបញ្ជាអោយមានប្រសិទ្ធិភាពខ្ពស់ ស្តីពីការងារបង្ការ និង ពន្លត់អគ្គិភ័យ ។
- អប់រំបុគ្គលិក អោយអនុវត្តតាមបទបញ្ជា ស្តីពីការងារបង្ការ និង ពន្លត់អគ្គិភ័យរបស់អង្គភាព ។

- រៀបចំប្រព័ន្ធបង្ការ និង ពន្លត់អគ្គិភ័យនៅគ្រប់មូលដ្ឋាន ក្រោមឱវាទ ។
- បណ្តុះបណ្តាលមុខជំនាញបច្ចេកទេស ដល់ភ្នាក់ងារបង្ការ និង ពន្លត់អគ្គិភ័យ ។
- ផ្សព្វផ្សាយ និង ណែនាំប្រជាពលរដ្ឋ អំពីវិធីបង្ការ និង ពន្លត់អគ្គិភ័យ ។
- ចាត់ត្រួតពិនិត្យកន្លែងបន្ទាន់ ដើម្បីស្រាវជ្រាវមូលហេតុនៃអគ្គិភ័យ ដែលកើតមាន ។
- ជួយសង្គ្រោះជនរងគ្រោះថ្នាក់ដោយអគ្គិភ័យ ។

មាត្រា ៣ : ត្រូវបានផ្ទេរក្របខ័ណ្ឌបុគ្គលិក ឧបករណ៍សំភារៈ និង មធ្យោបាយសំរាប់បំពេញការងារបង្ការ និង ពន្លត់អគ្គិភ័យ ពីក្រសួងមហាផ្ទៃ មកអោយរាជធានីភ្នំពេញគ្រប់គ្រង ។

មាត្រា ៤ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានគណៈកម្មាធិការប្រចាំរាជធានីភ្នំពេញ និង អស់លោកអភិបាលគ្រប់ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ — ព្រះហស្តលេខានិងត្រា — **នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី២ — ហត្ថលេខា និងត្រា — **ហ៊ុន សែន**